**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១៣២ អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពី**
**ការធ្វើអនុបយោគ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបទប្បញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- លិខិតលេខ ៥៣២ សជណ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ១៦២/២១ លស ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ របស់រដ្ឋបាលខេត្តព្រះសីហនុ។

## សម្រេច

**មាត្រា១.-**

ត្រូវបានធ្វើអនុប្បយោគផ្ទៃដីទំហំ ២០ ២៨៥ម៉ែត្រការ៉េ (ម្ភៃពាន់ពីររយប៉ែតសិបប្រាំម៉ែត្រការ៉េ) មានទីតាំងស្ថិតនៅភូមិគគីរ ឃុំបិទត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជូនលោក ប៉េង ជា តំណាងឱ្យលោកស្រី វិច ហុង ដូចមានក្នុងប្លង់គំនូសបង្ហាញទីតាំងដែលមាននិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២.-**

ផ្ទៃដីដែលបានធ្វើអនុប្បយោគដូចកំណត់ក្នុងមាត្រា១នេះ ត្រូវចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រង ព្រមទាំងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ក្នុងការលុបចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដើម្បីធ្វើប្រទានកម្មជូនលោក ប៉េង ជា តំណាងឱ្យលោកស្រី វិច ហុង ស្របតាមនីតិវិធីជាធរមាន។

**មាត្រា៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ២ កើតខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## គំនូសបង្ហាញទីតាំងដីវាស់វែងជាក់ស្តែងតាមការចង្អុលបង្ហាញរបស់ឈ្មោះ ប៉េង ជា តំណាងឱ្យលោកស្រី វិច ហុង
## ស្ថិតនៅភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

-យោងកំណត់ហេតុប្រជុំ ស្តីពីសំណើសុំគោលការណ៍កាត់ឆ្វៀលដីទំហំ ២០២៨៥ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ចេញពីដែនគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីអនុប្បយោគ និងប្រទានកម្មជាកម្មសិទ្ធិជូនលោក ប៉េង ជា តំណាងឱ្យលោកស្រី វិច ហុង ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ដឹកនាំដោយលោក គង់ វិតាណៈ អភិបាលរង នៃគណៈអភិបាលខេត្តព្រះសីហនុ

-យោងលិខិតអញ្ជើញលេខ៣០០/២១ លអជ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១ ចូលរួមពិនិត្យឯកសារ និងចុះហត្ថលេខាលើផែនទីករណីសំណើសុំកាត់ឆ្វៀលដីទំហំ ២០២៨៥ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ចេញពីដែនគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីអនុប្បយោគ និងប្រទានកម្មជាកម្មសិទ្ធិជូនលោក ប៉េង ជា តំណាងឱ្យលោកស្រី វិច ហុង ដឹកនាំដោយលោក គង់ វិតាណៈ អភិបាលរង នៃគណៈអភិបាលខេត្តព្រះសីហនុ




តារាងនិយាមការវាស់វែងជាក់ស្តែងតាមការចង្អុលបង្ហាញរបស់ឈ្មោះ ប៉េង ជា តំណាងឱ្យលោកស្រី វិច ហុង

| ID | Easthing | Northing |
|---|---|---|
| 1 | 343519.6081 | 1166297.182 |
| 2 | 343514.208 | 1166297.149 |
| 3 | 343498.204 | 1166297.051 |
| 4 | 343467.696 | 1166296.335 |
| 5 | 343457.188 | 1166296.298 |
| 6 | 343446.316 | 1166296.004 |
| 7 | 343432.16 | 1166296.145 |
| 8 | 343426.564 | 1166316.161 |
| 9 | 343403.014 | 1166312.812 |
| 10 | 343383.704 | 1166309.458 |
| 11 | 343371.844 | 1166306.888 |
| 12 | 343368.5684 | 1166305.691 |
| 13 | 343368.5684 | 1166355.658 |
| 14 | 343421.7337 | 1166450.174 |
| 15 | 343428.8342 | 1166457.275 |
| 16 | 343430.083 | 1166456.971 |
| 17 | 343434.249 | 1166456.414 |
| 18 | 343437.839 | 1166455.739 |
| 19 | 343448.729 | 1166453.624 |
| 20 | 343451.803 | 1166452.954 |
| 21 | 343462.333 | 1166451.024 |
| 22 | 343465.701 | 1166450.477 |
| 23 | 343470.052 | 1166449.711 |
| 24 | 343474.337 | 1166448.66 |
| 25 | 343481.485 | 1166447.167 |
| 26 | 343484.629 | 1166446.423 |
| 27 | 343487.721 | 1166445.668 |
| 28 | 343491.102 | 1166444.97 |
| 29 | 343502.616 | 1166442.239 |
| 30 | 343506.074 | 1166441.577 |
| 31 | 343509.414 | 1166440.47 |
| 32 | 343523.228 | 1166437.53 |
| 33 | 343529.0522 | 1166436.29 |
| 34 | 343528.9106 | 1166434.188 |
| 35 | 343526.5214 | 1166398.934 |
| 36 | 343525.4566 | 1166383.224 |
| 37 | 343522.3798 | 1166337.494 |